ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន

លេខ : ១៤៩ អគស.អល

# លិខិតអញ្ជើញ

**សូមអញ្ជើញ** : លោកជំទាវ ឧត្តមសេនីយ៍ទោ **រិន សិរីលក្ខិណា** អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ ជ ប ជ)

**ដើម្បីអញ្ជើញចូលរួម** : កិច្ចប្រជុំពិនិត្យ ពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា និងសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់ ស្តីពីកិច្ចសហ-ប្រតិបត្តិការអនុវត្តច្បាប់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត។

**ក្រោមអធិបតីភាព** : **ឯកឧត្តម ឡាំ ជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**ដែលនឹងប្រព្រឹត្តទៅ** : នៅថ្ងៃព្រហស្បតិ៍ ទី២២ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ០៨:៣០ នាទីព្រឹក

**ទីកន្លែង** : នៅសាលប្រជុំអគារ T-27 ទីស្តីការក្រសួងមហាផ្ទៃ

**សម្លៀកបំពាក់** : - ស៊ីវិល : **សមរម្យ**

- នគរបាលជាតិ-ពន្ធនាគារ : **ឯកសណ្ឋានការងារ។**

ថ្ងៃ អង្គារ ៥រោច ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២២

**អគ្គលេខាធិការស្តីទី**

**ម៉ែន ប៊ុនរិទ្ធ**

**សូមទំនាក់ទំនង:**

- លោកវរសេនីយ៍ឯក បូ រី ០១២ ៥៥២ ៥៥០
- លោកស្រីវរសេនីយ៍ទោ ឈរ ពុទ្ធារី ០៦១ ៧០៧ ០៣៧

# សេចក្តីព្រាងបឋម

# អនុស្សរណៈនៃការយោគយល់

# ស្តីពី

# កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់

# រវាង

# ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា

# និង

# ក្រសួងមហាផ្ទៃនៃសាធារណរដ្ឋសហព័ន្ធ

# នីហ្សេរីយ៉ា

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា (ចាប់ពីពេលនេះតទៅហៅថា "គូភាគី");

ដោយមានបំណងពង្រឹង និងបង្កើនទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា ក្នុងក្របខណ្ឌនៃគោលការណ៍គោរពអធិបតេយ្យ សមភាព និងផលប្រយោជន៍ទៅវិញទៅមក;

ដោយមើលឃើញភាពចាំបាច់ក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង និងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចអន្តរជាតិរបស់គូភាគី សំដៅធានាស្ថិរភាព ការពារសន្តិសុខ សុវត្ថិភាព និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋនៃប្រទេសទាំងពីរ;

ដោយពិចារណាលើកាតព្វកិច្ចស្របតាមច្បាប់ជាតិ និងអន្តរជាតិរបស់គូភាគី និងគោលការណ៍មូលដ្ឋានដូចមានចែងក្នុងលិខិតុបករណ៍អន្តរជាតិស្តីពីការការពារសិទ្ធិ និងសេរីភាពប្រជាពលរដ្ឋទាំងសងខាង;

បានព្រមព្រៀងដូចខាងក្រោម៖

## មាត្រា ១
## វិស័យនៃកិច្ចសហប្រតិបត្តិការ

គូភាគី ត្រូវសហការ តាមគ្រប់មធ្យោបាយ ដើម្បីទប់ស្កាត់ បង្ក្រាប និងស៊ើបអង្កេតបទល្មើសអនុលោមតាមច្បាប់ជាតិនៃប្រទេសរៀងៗខ្លួន និងសន្ធិសញ្ញាអន្តរជាតិ ដែលខ្លួនជាភាគី រួមមានជាអាទិ៍ដូចខាងក្រោម៖

ក) ឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង

ខ) ការផលិត ចរាចរ និងការជួញដូរគ្រឿងញៀនខុសច្បាប់ និងសារធាតុប៉ះពាល់សរសៃប្រសាទ

គ) ការឆបោកតាមប្រព័ន្ធប្រពន្ធ័បច្ចេកវិទ្យា

ឃ) ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការរំលោភបំពានផ្លូវភេទស្ត្រី និងកុមារ

ង) ការរត់ពន្ធជនទេសន្តប្រវេសន៍ និងទេសន្តប្រវេសន៍ខុសច្បាប់

ច) ការសម្អាតប្រាក់

ឆ) សកម្មភាពភេរវកម្ម រួមទាំង ការផ្តល់ហិរញ្ញប្បទានភេរវកម្ម

ជ) ការក្លែងក្រដាសប្រាក់ លិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារផ្លូវការផ្សេងទៀត

ញ) ការជួញដូរខុសច្បាប់នូវអាវុធ គ្រាប់រំសេវ គ្រឿងផ្ទុះ សារធាតុនុយក្លេអ៊ែរ ជីវសាស្ត្រ គីមីសាស្ត្រ វិទ្យុសកម្ម និងសារជាតិពុល

ដ) ការរត់ពន្ធទំនិញជាប់ពន្ធគយគ្រប់ប្រភេទ និងគ្រឿងស្រវឹង ផលិតផលថ្នាំជក់ និងប្រេងឥន្ធនៈ

ឋ) និងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត

# មាត្រា ២

## ទម្រង់ និងលក្ខខណ្ឌនៃកិច្ចសហប្រតិបត្តិការ

១- ទម្រង់កិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ ត្រូវរួមបញ្ចូលនូវការផ្លាស់ប្តូរព័ត៌មាន ការតាមស្វែងរក និងការកំណត់អត្តសញ្ញាណបុគ្គល និងវិធានការផ្សេងៗទៀត ស្របតាមគោលបំណងនៃអនុស្សរណៈនេះ អនុស្សរណៈអន្តរជាតិ និងច្បាប់ជាតិនៃប្រទេសរៀងៗខ្លួន។

២- រាល់ការស្នើសុំព័ត៌មាន ឬវិធានការផ្សេងៗ អនុលោមតាមអនុស្សរណៈនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ជាអក្សរអង់គ្លេស តាមផ្លូវការទូត ដោយអាជ្ញាធរមានសមត្ថកិច្ចនៃគូភាគី ដោយត្រូវភ្ជាប់ជាមួយឯកសារយោងពាក់ព័ន្ធ។

៣- ក្នុងករណីបន្ទាន់ សំណើអាចធ្វើឡើងដោយផ្ទាល់មាត់ ហើយត្រូវដាក់ជាលាយលក្ខណ៍អក្សរឲ្យបានឆាប់ មិនឲ្យលើសរយៈពេល ០៧ថ្ងៃ។(ប្រាំពីរ)

៤- ភាគីទទួលសំណើមានសិទ្ធិស្នើសុំព័ត៌មានបន្ថែមពីភាគីម្ចាស់សំណើ ប្រសិនបើយល់ឃើញថាមានភាពចាំបាច់សម្រាប់ការអនុវត្តសំណើឱ្យបានសមស្រប។

៥- ទោះបីមិនមានការស្នើសុំក៏ដោយ ភាគីម្ខាងអាចបញ្ជូនព័ត៌មានទៅភាគីម្ខាងទៀតបាន ប្រសិនបើមានមូលដ្ឋានជឿជាក់ថា ព័ត៌មាននោះមានប្រយោជន៍ដល់ភាគីម្ខាងទៀត។

៦- សំណើសុំត្រូវមាន៖

ក) ឈ្មោះអាជ្ញាធរនៃភាគីម្ចាស់សំណើ និងឈ្មោះអាជ្ញាធរនៃភាគីទទួលសំណើ

ខ) ព័ត៌មានលម្អិតអំពីករណីដែលត្រូវស្នើសុំ

គ) គោលបំណង និងមូលហេតុនៃការស្នើសុំ

ឃ) សេចក្តីពិពណ៌នាអំពីជំនួយដែលស្នើសុំ

ង) កម្រិតនៃភាពបន្ទាន់

ច) ព័ត៌មានផ្សេងទៀត ដែលអាចជួយឲ្យការអនុវត្តសំណើប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។

៧- ប្រសិនបើការអនុវត្តតាមការស្នើសុំជំនួយ ឬ សកម្មភាពសហប្រតិបត្តិការណាមួយ ធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យ ឬ សន្តិសុខ ឬ ផ្ទុយនឹងច្បាប់ជាតិ កាតព្វកិច្ចអន្តរជាតិ ឬ ផលប្រយោជន៍ចាំបាច់ផ្សេងទៀតរបស់ភាគីម្ខាង ភាគីដែលទទួលរងផលប៉ះពាល់នោះ អាចបដិសេធមិនអនុវត្តសំណើនោះ ត្រង់ផ្នែកខ្លះ ឬ ទាំងស្រុង ឬ អាចអនុវត្តសំណើក្រោមលក្ខខណ្ឌជាក់លាក់ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគីម្ចាស់សំណើ។

៨- ក្នុងករណីសំណើសុំត្រូវបានបដិសេធ ភាគីទទួលសំណើត្រូវជូនព័ត៌មានទៅភាគីម្ចាស់សំណើ អំពីការបដិសេធ និងមូលហេតុនៃការបដិសេធនេះ។

## មាត្រា ៣

## ដែនកំណត់លើការប្រើប្រាស់ព័ត៌មាន និងឯកសារ

១- គូភាគីព្រមព្រៀងថា ព័ត៌មាន និងទិន្នន័យបុគ្គល ដែលបានបញ្ជូនស្របតាមអនុស្សរណៈនេះ ត្រូវប្រើប្រាស់សម្រាប់គោលបំណងដូចមានចែងក្នុងអនុស្សរណៈនេះតែប៉ុណ្ណោះ ដោយត្រូវគោរពសិទ្ធិបុគ្គល អនុលោមតាមច្បាប់ជាតិ និងសន្ធិសញ្ញាសិទ្ធិមនុស្សពាក់ព័ន្ធ ដែលខ្លួនជាភាគី។

២- ទិន្នន័យបុគ្គល និង ជាពិសេស ព័ត៌មានសម្ងាត់ ដែលបានផ្លាស់ប្តូររវាងគូភាគី ត្រូវការពារស្របតាមបទដ្ឋានដូចគ្នាទៅនឹងការអនុវត្តចំពោះទិន្នន័យជាតិ និងអនុលោមតាមច្បាប់ជាតិ ឬ បទប្បញ្ញត្តិរបស់គូភាគីស្តីពីទិន្នន័យ និងព័ត៌មាន។

៣- គូភាគីត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ នូវទិន្នន័យព័ត៌មាន ឯកសារ និងសម្ភារទាំងឡាយ ដែលគូភាគីបានចែករំលែកទៅវិញទៅមក។ កាតព្វកិច្ចនៃការរក្សាការសម្ងាត់នេះ ត្រូវបន្តមានអានុភាពអនុវត្តដដែល ទោះបីក្រោយការបញ្ចប់ នៃកិច្ចព្រមព្រៀងនេះក៏ដោយ។

## មាត្រា ៤

## អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការអនុវត្តអនុស្សរណៈ

១- អាជ្ញាធរមានសមត្ថកិច្ចសម្រាប់អនុវត្តអនុស្សរណៈនេះមានដូចខាងក្រោម៖

ក) សម្រាប់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ៖ ក្រសួងមហាផ្ទៃ

ខ) សម្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា៖ ក្រសួងមហាផ្ទៃ

២- ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃ (សាមសិប)អនុស្សរណៈលាស់ នេះចូលជាធរមាន គូភាគីត្រូវផ្លាស់ប្តូរបញ្ជីឈ្មោះអង្គភាពចំណុះ ដែលមានសមត្ថកិច្ចទាក់ទងផ្ទាល់ លើការងារអនុវត្តបទប្បញ្ញត្តិនៃអនុស្សរណៈ
នេះ និងបង្កើតច្រកទំនាក់ទំនងពាក់ព័ន្ធ។

៣- គូភាគីត្រូវជូនដំណឹងទៅវិញទៅមកភ្លាមៗ អំពីការផ្លាស់ប្តូរអង្គភាពចំណុះ ដែលមានសមត្ថកិច្ចទាក់ទងផ្ទាល់ លើការងារអនុវត្តបទប្បញ្ញត្តិនៃអនុស្សរណៈនេះ។

## មាត្រា ៥

## ការពិគ្រោះយោបល់

ភាគីទាំងពីរត្រូវធ្វើការពិគ្រោះយោបល់គ្នា នៅរាល់ពេលមានតម្រូវការ ឬ ក្នុងករណីខ្លះ ត្រូវធ្វើឡើងទៀងរាល់ឆ្នាំ ដើម្បីវាយតម្លៃ ការវិវត្តន៍ក្នុងបរិបទនៃអនុស្សរណៈនេះ ព្រមទាំងដើម្បីកែសម្រួល និងពង្រឹងកិច្ចសហប្រតិបត្តិការនេះ។

## មាត្រា ៦
## ការដោះស្រាយវិវាទ

វិវាទដែលអាចកើតចេញពីការបកស្រាយ ឬការអនុវត្តអនុស្សរណៈនេះ ត្រូវដោះស្រាយក្នុងស្មារតីមិត្តភាព តាមរយៈការពិគ្រោះយោបល់រវាងអាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងនៅក្នុងមាត្រា ៦ វាក្យខណ្ឌ ១ និងតាមរយៈការចរចាតាមផ្លូវការទូត។

## មាត្រា ៧
## ទំនាក់ទំនងនៃអនុស្សរណៈនេះជាមួយសន្ធិសញ្ញាអន្តរជាតិដទៃទៀត

អនុស្សរណៈនេះមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ច កើតចេញពីសន្ធិសញ្ញាអន្តរជាតិដទៃទៀត ដែលភាគីនីមួយៗបានចុះហត្ថលេខារួចហើយនោះឡើយ។

## មាត្រា ៨
## ការចំណាយផ្សេងៗ

ការចំណាយផ្សេងៗសម្រាប់ដំណើរការសំណើក្រោមអនុស្សរណៈនេះ ជាបន្ទុករបស់ភាគីទទួលសំណើ ឬ ធ្វើឡើងតាមការព្រមព្រៀងរបស់គូភាគី។

## មាត្រា ៩
## អវសានបញ្ញត្តិ

១- អនុស្សរណៈនេះ ចូលជាធរមាននៅថ្ងៃទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរលើកចុងក្រោយ ដែលភាគីម្ខាងបានផ្ញើជូនភាគីម្ខាងទៀតតាមរយៈស្ថានទូត អំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងចាំបាច់សម្រាប់ការចូលជាធរមាន។

២- អនុស្សរណៈនេះមានសុពលភាពក្នុងរយៈពេល ០៣ឆ្នាំ។ ភាគីម្ខាងអាចជូនដំណឹងភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរតាមរយៈស្ថានទូត ក្នុងពេលណាក៏បាន ប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈនេះ។ ក្នុងករណីនេះ អនុស្សរណៈនេះនឹងបញ្ចប់ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។ ការបញ្ចប់អនុស្សរណៈនេះ មិនមានផលប៉ះពាល់ដល់ការអនុវត្តភារកិច្ច ដែលមិនទាន់បានបញ្ចប់ទាំងឡាយណា ដែលបានព្រមព្រៀងកន្លងមកនោះទេ។

៣- ក្រោយអនុស្សរណៈនេះចូលជាធរមាន ភាគីម្ខាងអាចស្នើភាគីម្ខាងទៀតសុំធ្វើវិសោធនកម្ម ឬ បំពេញបន្ថែមលើអត្ថបទអនុស្សរណៈនេះបាន។ វិសោធនកម្ម ឬការបំពេញបន្ថែមត្រូវចូលជាធរមានស្របតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។

អនុស្សរណៈនៃការយោគយល់នេះ ត្រូវចុះហត្ថលេខា នៅថ្ងៃទី............ខែ................ឆ្នាំ២០២........ នៅរាជធានី/រដ្ឋធានី............នៃព្រះរាជាណាចក្រកម្ពុជា/សាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា។ អនុស្សរណៈនេះ ធ្វើឡើងជា ០២ (ពីរ) ច្បាប់ដើម ជាអក្សរខ្មែរ និងអក្សរអង់គ្លេស ដែលសំណៅនៃច្បាប់ដើមនីមួយៗមានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា សំណៅជាអក្សរអង់គ្លេសត្រូវយកជាគោល។

**តំណាងក្រសួងមហាផ្ទៃ**
**នៃព្រះរាជាណាចក្រកម្ពុជា**

**តំណាងក្រសួងមហាផ្ទៃ**
**នៃសាធារណរដ្ឋសហព័ន្ធនីហ្សេរីយ៉ា**